នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Oct-2016, 09:25
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខផ្សេងៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ

# I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាសូមឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ[1] របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[2] ("អជសដ") ចំពោះសំណើសុំ[3] ការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

២. អាស្រ័យដូចមូលហេតុកំណត់ខាងក្រោម អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវថា ខ្លួនមិនត្រូវបានប្តឹងតាមរយៈដីកាដំណោះស្រាយនៃសំណុំរឿង០០២ ចំពោះការចោទប្រកាន់អំពីអង្គហេតុដែលជាប់ទាក់ទងនឹង ការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខស-២១ ហើយនិងមន្ទីរសន្តិសុខក្រាំងតាចាន់ទេ។ សចស បានច្រានចោលការចោទអំពីអង្គហេតុទាំងអស់នេះនៅក្នុងដីកាដំណោះស្រាយ។ ការអះអាងផ្ទុយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺបណ្តាលមកពីការយល់ច្រឡំនៃខ្លឹមសារក្នុងដីកាដំណោះស្រាយ និងការប្រើប្រាស់ច្បាប់ខុស។ ការបកស្រាយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានមើលរំលងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជូនដំណឹងនៅក្នុងដីកាដំណោះស្រាយអំពីប្រភេទនៃបទចោទប្រកាន់ប្រឆាំងនឹងខ្លួន រួមទាំងទម្រង់នៃការទទួលខុសត្រូវណាមួយដែលបានចោទប្រកាន់ ហើយនឹងលក្ខខណ្ឌតម្រូវដែលថា ការរកឃើញអំពីអង្គហេតុ និងអង្គច្បាប់នៅក្នុងដីកាដំណោះស្រាយ ត្រូវបង្កើតឲ្យមានទំនាក់ទំនងមួយរវាងអំពើប្រព្រឹត្តរបស់ជនជាប់ចោទ និងឧក្រិដ្ឋកម្មណាមួយដែលបានចោទប្រកាន់។

៣. ដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំតុលាការកំពូល ("អជតក") បដិសេធសំណើសុំនេះ។

# II. ប្រវត្តិនីតិវិធី

[1] **E306/7/3/1/1** បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើសុំការបញ្ជាក់ពីវិសាលភាពទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ, ២៨ កញ្ញា ២០១៦ (ដែលបានជូនដំណឹងមកភាគីជាភាសាខ្មែរ និងអង់គ្លេស នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦) ("បណ្តឹងសាទុក្ខ")។

[2] **E306/7/3** សេចក្តីសម្រេចលើសារណារបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ, ៣០ សីហា ២០១៦ ("សេចក្តីសម្រេច")។

[3] **E306/7** សារណារបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/២ ទាក់ទងនឹបទចោទនៃការរំលោភ សេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ, ១៨ មីនា ២០១៦ ("សំណើ")។

៤. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត ("សចស") បានចេញដីកាដំណោះស្រាយ[4]របស់ខ្លួនក្នុងសំណុំរឿង០០២ ដោយធ្វើការចោទប្រកាន់បុគ្គលបួននាក់ ក្នុងនោះរួមមានជនជាប់ចោទទាំងពីរនាក់ផង ចំពោះឧក្រិដ្ឋកម្មទាំងឡាយរួមទាំង បទរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(ក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ)។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ ("អបជ") បានចេញសាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាំងបីដែលប្រឆាំងនឹងដីកាដំណោះស្រាយ ដោយមានការដាក់បញ្ចូលជំនួសនូវការកំណត់បទចោទអំពី ការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភសេពសន្ថវៈដាច់ដោយឡែក ជាមួយនឹងការកំណត់បទចោទរបស់ខ្លួនជា អំពើអមនុស្សធម៌ផ្សេងៗទៀត[5]។

៥. នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២[6] ដោយបានបង្កើនបញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២[7]។ បីសប្ដាហ៍ក្រោយមកនៅថ្ងៃទី២៥ ខែ មេសា ឆ្នាំ២០១៤ នៅក្នុងចម្លើយតបទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី "កំណត់សំអាងហេតុនៃការទទួលខុសត្រូវសាជាថ្មីចំពោះអំពើរំលោភសេពសន្ថវៈ ដែលស្ថិតនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ"[8] ដោយឈរលើទឡ្ហីករណ៍ថា"សំអាងហេតុរបស់[សចស] ដែលពុំបានផ្ដន្ទាទោសជនជាប់ចោទចំពោះអំពើរំលោភសេពសន្ថវៈ ដែលស្ថិតនៅក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ គឺមានការភាន់ច្រឡំ"[9] អង្គជំនុំជម្រះសាលាដំបូងបានបញ្ចេញនូវ"ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅ

---

4 **D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០ ("ដីកាដំណោះស្រាយ")។

5 **D427/1/26** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៣ មករា ២០១១, ទំព័រ៤។ **D427/2/12** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៣ មករា ២០១១, ទំព័រ៦។ **D427/4/14** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៣ មករា ២០១១, ទំព័រ៤។

6 **E301/9/1** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២, ៤ មេសា ២០១៤ ("សេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម")។

7 **E301/9/1.1 ឧបសម្ព័ន្ធ:** បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿងលេខ ០០២/០២, ៤ មេសា ២០១៤ ("ឧបសម្ព័ន្ធស្ដីពីវិសាលភាពនៃសំណុំរឿង០០២/០២")។

8 **E99/1** ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ២១ កក្កដា ២០១១ ("ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងការរំលោភសេពសន្ថវៈ"), កថាខណ្ឌ៤៤(ii)។ សូមមើលផងដែរកថាខណ្ឌ៤០, ៤៣។

9 **E99/1** ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងការរំលោភសេពសន្ថវៈ, កថាខណ្ឌ៤០។

សេសសល់"[10]។ ក្នុងសេចក្ដីសម្រេចនោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនបានរកឃើញថា ដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ មិនបានចោទប្រកាន់ជនជាប់ចោទទាំងពីរ ពីបទរំលោភសេពសន្ថវៈក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមទម្រង់នៃការទទួលខុសត្រូវទេ៖

> អង្គជំនុំជម្រះយល់ឃើញថា ពុំមានមូលដ្ឋានច្បាប់សម្រាប់ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំបន្ថែមទៅក្នុងដីកាដំណោះស្រាយនូវ បទចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ (ក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ) ដែលបានប្រព្រឹត្តក្នុងមន្ទីរសន្តិសុខនានាឡើយ (ឯកសារ E99/1, កថាខណ្ឌ 32-41, 43, 45)។ សហចៅក្រមស៊ើបអង្កេតបានរកឃើញចំៗថា ខណៈមានការរំលោភសេពសន្ថវៈបានកើតឡើងនៅតាមមន្ទីរសន្តិសុខនានាមែន ឧក្រិដ្ឋកម្មទាំងនេះមិនអាចយកមកធ្វើទំនាក់ទំនងទៅនឹងជនជាប់ចោទបានទេ ដោយសារពុំមានភស្តុតាងគាំទ្រដែលថា មេដឹកនាំ បកក បានប្រើប្រាស់ការរំលោភសេពសន្ថវៈ ជាគោលនយោបាយមួយនៅតាមមន្ទីរសន្តិសុខនានា (ឯកសារ D427, កថាខណ្ឌ 1426-1429 )។ ទោះបីជាអង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទ ដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយក៏ដោយ ក៏ប៉ុន្តែអង្គជំនុំជម្រះ *មិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ* (វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង)។ អង្គជំនុំជម្រះពុំមានសិទ្ធិអំណាចបញ្ចូលអង្គហេតុ ឬ បទចោទថ្មីទៅក្នុងដីកាដំណោះស្រាយដែលអង្គហេតុ ឬបទចោទនោះត្រូវបានបដិសេធដោយ[សចស] ហើយដែល[អបជ]ពុំមានជំហរផ្សេងពីសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះ[11]។

គ្មានភាគីណាមួយបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចនេះទេ។

៦. នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចបន្ថែមមួយទៀត ដោយថ្លែងថា ៖

> ទាក់ទងនឹងចំណុចនេះ [សចស] បានរកឃើញថា ការរំលោភសេពសន្ថវៈបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងចំណោមទីកន្លែងផ្សេងទៀត។ ប៉ុន្តែ [សចស] បានរកឃើញថា ការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ មិនអាចត្រូវបានចាត់ទុកថាជា ឧក្រិដ្ឋកម្មកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្ម ដែលបានប្រើប្រាស់ដោយមេដឹកនាំ បកក ដើម្បីអនុវត្តគោលបំណងរួមនៃសហកម្មឧក្រិដ្ឋកម្មរួមទេ។ ដីកាដំណោះស្រាយ ក៏មិនបានចោទ

[10] **E306** ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់, ២៥ មេសា ២០១៤ ("សេចក្ដីសម្រេចរបស់ អជសដ ស្ដីពីអញ្ញត្រកម្ម")។

[11] **E306** សេចក្ដីសម្រេចរបស់ អជសដ ស្ដីពីអញ្ញត្រកម្ម, កថាខណ្ឌ៣ (សង្កត់ន័យដើម)។

ប្រកាន់ថា ជនជាប់ចោទមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការរំលោភសេពសន្ថវៈនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយផ្អែកទៅលើទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតដែរ[12]។

ចំពោះសេចក្តីសម្រេចចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤នេះ គ្មានភាគីណាមួយបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះទេ។

៧. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ គឺមួយឆ្នាំបន្ទាប់ពីការផ្តល់សក្ខីកម្មរបស់សាក្សីក្នុងសំណុំរឿង០០២/០២ បានចាប់ផ្តើម ហើយមានរយៈពេលស្ទើរតែពីរឆ្នាំ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ដែលបញ្ជាក់ថា ការរំលោភសេពសន្ថវៈនៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ មិនត្រូវបានចោទប្រកាន់ប្រឆាំងជនជាប់ចោទនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានដាក់សំណើសុំ។ ក្នុងសំណើសុំនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើជាពិសេសសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ផ្តល់ការបញ្ជាក់បំភ្លឺបន្ថែមលើបញ្ហាដដែល ដែលបានសម្រេចយ៉ាងច្បាស់រួចហើយនៅក្នុងសេចក្តីសម្រេចពីមុន និងដើម្បីឱ្យដឹងថា ខ្លួនត្រូវបានប្តឹងដោយដីកាដំណោះស្រាយជាមួយនឹងការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈនៅសហករណ៍ត្រាំកក់ និងនៅមន្ទីរសន្តិសុខស-២១ និងក្រាំងតាចាន់ ក្នុងសំណុំរឿង០០២/០២[13]។ ខៀវ សំផន បានឆ្លើយតបនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦[14] ហើយដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦[15]។ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើនេះ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦[16]។

៨. នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងសាទុក្ខ។ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃ អជតក នៅក្នុងសារអេឡិចត្រូនិកមួយជូនមន្ត្រីទទួល

---

12 **E348/4** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ថន និងដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និងស្នើសុំឯកសារថតចម្លងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន, ១២ មិថុនា ២០១៥ (“សេចក្តីសម្រេចរបស់ អជសដ ស្តីពីការតទល់គ្នា”), កថាខណ្ឌ១១ (សេចក្តីយោងខាងក្នុងត្រូវបានលុបចេញ)។

13 **E306/7** សំណើ, កថាខណ្ឌ១, ២៨។

14 **E306/7/1** ចម្លើយរបស់មេធាវីការពារក្តី លោក ខៀវ សំផន ទៅនឹងសំណើសុំបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបទចោទនៃការរំលោភសេពសន្ថវៈ, ២៨ មីនា ២០១៦ (Réponse de la Défense de M. Khieu Samphan à la demande de clarification des Parties civiles concernant les accusations de viol, 28 March 2016)។

15 **E306/7/2** ការឆ្លើយតបរបស់សហមេធាវីនាំមុខទៅនឹងចម្លើយរបស់មេធាវីការពារក្តី ខៀវ សំផន តបសំណើសុំការបញ្ជាក់ បំភ្លឺស្តីពីការរំលោភសេពសន្ថវៈនៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ, ៤ មេសា ២០១៦ (“ការឆ្លើយតប”)។

16 **E306/7/3** សេចក្តីសម្រេច។

បន្ទុកសំណុំរឿង[17] បានកត់សំគាល់ថា បណ្ដឹងសាទុក្ខបានដាក់ជូន អជតក ដោយភាន់ច្រឡំដែលជាការរំលោភវិធាន១០៦(១)និង(២)[18]នៃវិធានផ្ទៃក្នុង។ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ការសម្រេចរបស់ អជតក នាពេលអនាគត ពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃការដាក់ឯកសារ គាត់បានស្នើឲ្យមន្ត្រីទទួលសំណុំរឿង បញ្ជូនបណ្ដឹងសាទុក្ខទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីចំណាត់ការ។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងអំពីបណ្ដឹងសាទុក្ខនេះ ដល់ភាគីនានានៃសំណុំរឿង០០២ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦។

៩. នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ អជតក បានផ្ដល់ការអនុញ្ញាតតាមសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ជាភាសាអង់គ្លេសជាមុន ចំណែកច្បាប់បកប្រែជាភាសាខ្មែរ នឹងដាក់មិនឲ្យហួសពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦[19]។

## III. ច្បាប់ជាធរមាន

## ភាពអាចទទួលយកបាន

១០. វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ចែងថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង "ដែលមានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" ត្រូវបានបើកផ្លូវឲ្យប្ដឹងសាទុក្ខភ្លាមៗ។

១១. វិធាន ១០៧(១) នៃវិធានផ្ទៃក្នុង ចែងថា "ក្នុងករណីដែលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បើកឲ្យមានបណ្ដឹងសាទុក្ខភ្លាមៗនៅក្រោមវិធាន១០៤(៤)(ក) និង(ឃ) បណ្ដឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេចនោះ"។

## បទដ្ឋាននៃការត្រួតពិនិត្យបណ្ដឹងសាទុក្ខ

១២. អនុលោមតាមវិធាន ១០៤(១) និង ១០៥(២) នៃវិធានផ្ទៃក្នុង បណ្ដឹងសាទុក្ខភ្លាមៗអាចត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានចំនួនបី ដូចខាងក្រោម៖

- កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈលើសេចក្ដីសម្រេចនោះ
- កំហុសនៃអង្គហេតុ ដែលនាំឲ្យសេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌ ឬ

---

[17] សារអេឡិចត្រូនិក មានចំណងជើងថា "ដាក់ឯកសារថ្មីៗក្នុងសំណុំរឿង០០២/០២" ពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់នៃ អជតក Volker Nerlich ជូនមន្ត្រីសំណុំរឿង, ១១ តុលា ២០១៦ នៅម៉ោង ២:២៤ រសៀល។

[18] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី៩, ១៦ មករា ២០១៥ ("វិធានផ្ទៃក្នុង") ("វិធាន")។

[19] សារអេឡិចត្រូនិក ពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់នៃ អជតក Volker Nerlich មានចំណងជើងថា "យោង: សំណើសុំដាក់ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ ជាភាសាមួយ", ១៩ តុលា ២០១៦ នៅម៉ោង ២:១៣ រសៀល។

- កំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ[20]។

## អង្គសេចក្តី

១៣. វិធាន ៦៧ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងដីកាដំណោះស្រាយដែលបានចេញដោយ សចស ចែងផ្នែកដែលពាក់ព័ន្ធថា ៖

១. [សចស] ត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ [...]

២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និង *ប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ* បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយសារកំហុសនីតិវិធី (សង្កត់ន័យដើមត្រង់អក្សរទ្រេត)។

៣. [សចស] ត្រូវចេញដីកាលើកលែងចោទប្រកាន់ ក្នុងករណីដូចខាងក្រោម៖
ក) អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។
...
គ) ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ។

៤. ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។ ដីកានេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើជាក់លាក់ណាមួយ ឬប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត។

១៤. វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ចែងថា “អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ”។

១៥. វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ចែងថា “សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទ

[20] សូមមើលបន្ថែម **E50/1/1/4** សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់, ៣ មិថុនា ២០១១, កថាខណ្ឌ២៧។

ចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ។ [...]"

## IV. សេចក្តីសន្និដ្ឋាន
## ភាពអាចទទួលយកបាន

១៦. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា បណ្តឹងសាទុក្ខអាចទទួលយកបាន តាមវិធាន១០៤(៤)(ក) ដោយសារសេចក្តីសម្រេចដែលមានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី[21] ផ្អែកលើមូលដ្ឋានថា ការចេញសេចក្តីសម្រេចទាំងនេះមានអនុភាពក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី ទាក់ទងនឹងការចោទប្រកាន់ផ្អែកអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ[22]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចង្អុលទៅរក ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា "បទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ក្នុងវាក្យខណ្ឌសម្រេចសេចក្តីនៃ ដីកាដំណោះស្រាយនោះ គឺត្រូវបកស្រាយថាជាការមិនរាប់បញ្ចូលនូវអំពើរំលោភសេពសន្ថវៈដែលបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ និងសហករណ៍នានា នៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ពុំមានបទឧក្រិដ្ឋដែលបានចោទប្រកាន់ដទៃទៀតបានពឹងផ្អែកទៅលើមូលដ្ឋាននៃអង្គហេតុនៃ ការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំទេ[23]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតវ៉ាថា ការរកឃើញនេះ "នាំឱ្យមានការចាប់អារម្មណ៍ដោយភាន់ច្រឡំ ឬផ្សេងពីនេះថា វាជាការចោទប្រកាន់ផ្អែកអង្គហេតុដែលមិនបានបង្កើតជាផ្នែកនៃ*ការបញ្ជូន* របស់អង្គជំនុំជម្រះសាលាដំបូង"[24]។ តាមការយល់ឃើញរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺថា ដោយសារ សចស មិនបានច្រានចោលការចោទប្រកាន់ផ្អែកអង្គហេតុនៃ ការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ទើបវានៅតែស្ថិតក្នុងវង្វង់នៃ*ការបញ្ជូន* របស់អង្គជំនុំជម្រះសាលាដំបូងដដែល[25] រហូតដល់ពេលមានសេចក្តីសម្រេចច្រានចោលអង្គហេតុទាំងនោះតាមការសម្រេចនេះ។

១៧. អាស្រ័យដោយមូលហេតុដូចបានកំណត់ខាងក្រោម អង្គសេចក្តីនៃអំណះអំណាងនេះ បានពឹងផ្អែកលើការបកស្រាយខុសទាំងលើផ្នែកច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ។ តាមការបកស្រាយដ៏ត្រឹមត្រូវមួយទាំងអង្គហេតុនិងអង្គច្បាប់ គេច្បាស់ណាស់ថា សចស មិនបានចោទប្រកាន់ជនជាប់ចោទ ចំពោះការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយ

---

[21] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ២២-២៣, ៥០-៦៦។

[22] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៥០។

[23] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៦៣ *យោង* ឯកសារ **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៥។

[24] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៦៤។

[25] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ២២-២៣, ៥១-៦២។

បង្ខំទេ ហើយថា ការចោទប្រកាន់ផ្នែកអង្គហេតុទាក់ទងនឹងបទឧក្រិដ្ឋនេះ ត្រូវបានច្រានចោលរួចហើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមិនធ្លាប់បានទទួលអង្គហេតុទាំងនេះឡើយ ចំណែកឯសេចក្តីសម្រេចចុះខែមេសា ឆ្នាំ២០១៤, ខែមិថុនា ឆ្នាំ២០១៥ និងខែសីហា ឆ្នាំ២០១៦ គ្រាន់តែបានបញ្ជាក់អះអាងចំពោះរឿងនេះប៉ុណ្ណោះ។ អាស្រ័យហេតុនេះ សេចក្តីសម្រេចមិនមានអនុភាពដើម្បី "បញ្ចប់កិច្ចដំណើរការនីតិវិធី" ឡើយ ដោយសារវានៅតែគ្មាន "កិច្ចដំណើរការនីតិវិធី" ណាមួយដើម្បីបញ្ចប់នោះទេ។

១៨. លើសពីនេះ តាមរយៈការដាក់សំណើសុំរបស់ខ្លួនដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការសម្រេចពីរដងរួចមកហើយនោះ និងបន្ទាប់មក តាមរយៈការប្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលដូចគ្នាបេះបិទនេះ គឺសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែគេចវេះពីពេលវេលាកំណត់ដែលមានអនុភាពរយៈពេល៣០ថ្ងៃ[26] សម្រាប់ការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចពីមុនៗនោះ។

១៩. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងសាទុកនេះគ្មានអង្គសេចក្តីទេ មិនអាចទទួលយកបាននៅក្រោមវិធាន១០៤(៤) និងមិនត្រូវតាមពេលវេលាឡើយនៅក្រោមវិធាន១០៧(១) ដូច្នេះបណ្តឹងនេះគួរតែត្រូវបានបដិសេធចោល។

## អង្គសេចក្តី

*អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវថា ខ្លួនមិនត្រូវបានប្តឹងតាមរយៈដីកាដំណោះស្រាយនៃសំណុំរឿង០០២ទេ ចំពោះការចោទប្រកាន់អំពីអង្គហេតុដែលជាប់ទាក់ទងនឹងការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

២០. បណ្តឹងសាទុក្ខ ត្រូវបានធ្វើឡើងដោយពឹងផ្អែកលើទឡ្ហីករណ៍ចំនួនពីរ។ ទីមួយ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តល់មតិដែលមានសំអាងហេតុណាមួយចំពោះបញ្ហានៃ*ការបញ្ជូន* នៃបទចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈនៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខ ស-២១ និងក្រាំងតាចាន់ទេ ផ្ទុយទៅវិញគេផ្តល់នូវការកំណត់មួយនៅលើបញ្ហានៃការកំណត់បទចោទចំពោះ បទចោទប្រកាន់ផ្នែកអង្គហេតុទាំងនេះទៅវិញ ដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា មិនបង្កើតបានជាផ្នែកនៃសំណើសុំរបស់ពួកគេ[27]។ ពួកគេអះអាងថា នេះគឺជាកំហុសមួយស្តែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី[28]។ ទីពីរ ពួកគេសន្និដ្ឋានថាអង្គជំនុំជម្រះសាលាដំបូង

---

[26] វិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។

[27] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៧៣-៨១។

[28] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៧៣, ៧៥។

បានប្រព្រឹត្តនូវកំហុសមួយផ្នែកច្បាប់នៅពេលធ្វើការសន្និដ្ឋាន ក្នុងពេលអវត្តមាននៃដីកាសម្រេចច្រានចោលច្បាស់លាស់ ធ្វើឲ្យការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ មិនត្រូវបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយដែលប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង[29]។

២១. ដោយសារសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាចំពោះទឡ្ហីករណ៍ទាំងពីរនៃបណ្តឹងសាទុក្ខ កើតចេញពីការវិភាគតែមួយនៃបរិបទនៃដីកាដំណោះស្រាយនៃសំណុំរឿង០០២ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាសូមលើកពីបញ្ហាទាំងនេះរួមគ្នា។

២២. ត្រឡប់ទៅរកការពាក្យថា ដីកាដំណោះស្រាយ គឺដូចគ្នានឹងអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សំគាល់ដែរថា[30] ឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈនៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានប្រព្រឹត្តនៅតាមបណ្តាទីតាំងនានា រួមទាំង ស២១ ក្រាំងតាចាន់និងសហករណ៍ត្រាំកក់ផង[31]។ ប៉ុន្តែតាមការអានជាធម្មតានៃដីកាដំណោះស្រាយ សចស មិនបានរកឃើញអង្គហេតុ ឬអង្គច្បាប់ដែលអាចភ្ជាប់ឧក្រិដ្ឋកម្មទាំងនេះទៅជនជាប់ចោទទេ។ ដូច្នេះហើយបានជា សចស ទាត់ចោលបញ្ហានេះស្របទៅតាមវិធាន៦៧(៣)[32] និងតាមរយៈអំណះអំណាងដែលមានសំអាងហេតុចំពោះ *ការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ* ដោយសារតែពួកគេមិនបានពិចារណាថា ជនជាប់ចោទមានការទទួលខុសត្រូវចំពោះបទចោទប្រកាន់នេះ នៅក្រោមទម្រង់នៃការទទួលខុសត្រូវដែលមានចែងនៅក្នុងមាត្រា២៩ថ្មី នៃច្បាប់ អ.វ.ត.ក[33]។

២៣. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ស្រប[34]ថា កថាខណ្ឌ ១៤២៨-១៤២៩ នៃដីកាដំណោះស្រាយ ផ្តល់មូលហេតុនានាសម្រាប់ការច្រានចោលលទ្ធភាពដែលថាជនជាប់ចោទអាចនឹងត្រូវបានចោទប្រកាន់ចំពោះ ការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនៅក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយផ្អែកលើមូលដ្ឋាននៃការប្រព្រឹត្តតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ("JCE")៖ តាមទស្សនៈយល់ឃើញរបស់ សចស "គោលនយោបាយផ្លូវការរបស់ បកក ទាក់ទងនឹងការរំលោភសេពសន្ថវៈ គឺដើម្បីទប់ស្កាត់កុំឲ្យកើតឡើងនូវការរំលោភសេពសន្ថវៈ និងដើម្បីផ្តន្ទាទោសចំពោះអ្នកប្រព្រឹត្ត"[35] ហើយ "វាមិនអាចឲ្យគេពិចារណាថា ការរំលោភសេពសន្ថវៈ គឺជាបទឧក្រិដ្ឋមួយ

---

[29] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៨២-៩១។

[30] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៣-១៤ *យោង* **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៤២៦-១៤២៧។

[31] **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៤២៦-១៤២៨។

[32] វិធាន៦៧(៣)(គ) ("[សចស] ត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម៖ [...] គ) ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ")។

[33] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ *ដែលបានធ្វើវិសោធនកម្ម* នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

[34] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៥៥។

[35] **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៤២៩។

ដែល បកក បានប្រើប្រាស់ដើម្បីអនុវត្តគោលបំណងរួម"[36]បានឡើយ។ ការរកឃើញទាំងនេះ ក៏បង្ហាញឲ្យឃើញថា សចស មិនបានពិចារណាថា ជនជាប់ចោទបានធ្វើផែនការ បញ្ជា ញុះញង់ ឬជួយនិងទំនុបបម្រុងដល់ការប្រព្រឹត្តបទរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ដែរ។ តាមរយៈការរកឃើញថាគោលនយោបាយផ្លូវការរបស់ បកក គឺដើម្បីទប់ស្កាត់កុំឲ្យកើតឡើងនូវការរំលោភសេពសន្ថវៈ និងដើម្បីផ្តន្ទាទោសចំពោះការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ សចស បានផ្តល់សំអាងហេតុយ៉ាងគ្រប់គ្រាន់ដល់ការសន្និដ្ឋានរបស់ខ្លួនថា ពួកគេមិនបានរកឃើញថា ជនជាប់ចោទមានការទទួលខុសត្រូវក្នុងនាមថ្នាក់លើចំពោះឧក្រិដ្ឋកម្មទាំងនោះទេ។ ការរកឃើញថា ក្នុងពេលដែល "គោលនយោបាយ បកក មិនអាចរកវិធីទប់ស្កាត់បានចំពោះការរំលោភសេពសន្ថវៈ" មិនស៊ីសង្វាក់គ្នានឹងការសន្និដ្ឋាននេះឡើយ។ លើសពីនេះដីកាដំណោះស្រាយពុំមានការរកឃើញអំពីអង្គហេតុ ឬអង្គច្បាប់ដែលអាចនឹង*គាំទ្រ* ចំពោះការសម្រេចមួយដែលថាជនជាប់ចោទអាចនឹងត្រូវបានដាក់ឲ្យស្ថិតក្រោមការទទួលខុសត្រូវ ចំពោះការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្រោមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើទេ។ ពុំមានការរកឃើញថា ជនជាប់ចោទបានដឹង ឬមានហេតុផលនឹងដឹងពីការរំលោភសេពសន្ថវៈទាំងនេះ តែខកខានមិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ ឬផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មទាំងនេះ។

២៤. ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញហេតុផលដូច្នោះដែរ[37] សេចក្តីសន្និដ្ឋានដែលថា សចស មិនបានរកឃើញថាជនជាប់ចោទដែលទទួលខុសត្រូវនៅក្រោមទម្រង់ *ណាមួយក៏ដោយ* នៃការទទួលខុសត្រូវចំពោះការរំលោភសេពសន្ថវៈនៅខាងក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ គឺត្រូវបានបកស្រាយបង្ហាញដោយការយោងទៅរក "ការរកឃើញតាមផ្លូវច្បាប់ស្តីពីទម្រង់នៃការទទួលខុសត្រូវ" របស់ពួកគេ។ ទាក់ទងនឹងការចូលរួមចំណែកតាមរយៈ JCE, ជនជាប់ចោទត្រូវបានចោទប្រកាន់អំពីការរំលោភសេពសន្ថវៈតែនៅក្នុងការជាប់ទាក់ទងនឹងបទបញ្ជារបស់ បកក ស្តីពីការរៀបការ ប៉ុណ្ណោះ[38]។ ចំពោះរាល់ទម្រង់ផ្សេងៗទៀតនៃការទទួលខុសត្រូវ សចស បានថ្លែងយ៉ាងច្បាស់ថា ជនជាប់ចោទត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្តីពី "ការរំលោភសេពសន្ថវៈ*នៅក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ*"[39]។ ដោយសារមានតែការចោទប្រ

[36] **D427** *ដដែលដូចខាងលើ*។

[37] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៥។

[38] **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៥២៥។

[39] **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៤៥ (ការធ្វើផែនការ), ១៥៤៨ (ការញុះញង់), ១៥៥១ (ការជួយ និងការជំរុញ), ១៥៥៤ (ការបញ្ជា), ១៥៥៩ (ការទទួលខុសត្រូវរបស់ថ្នាក់លើ)។ អង្គហេតុដែលថាអាកប្បកិរិយាដែលបង្កើតឲ្យមានជាការរំលោភសេពសន្ថវៈអាចនឹងបង្កោនតាមការកំណត់បទចោទដទៃទៀត ដូចជា ការធ្វើទារុណកម្ម ឬការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដូចជាអំពើអមនុស្សធម៌ផ្សេងៗទៀតដែលមិនផ្លាស់ប្តូរដល់សេចក្តីសន្និដ្ឋាននេះនោះទេ។ សចស ធ្លាប់បានរកឃើញថា*អង្គហេតុ* ដែលនាំឲ្យមានជាឧក្រិដ្ឋកម្មនៃការរំលោភ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បើពួកគាត់បានពិចារណាលើអង្គហេតុទាំងនេះថាអាចជាប់ទៅនឹងជនជាប់ចោទ ពួកគាត់មុខជាដាក់បញ្ចូលពួកវាថា *ជាការរំលោភសេពសន្ថវៈ* នៅក្នុងបញ្ជីឧក្រិដ្ឋកម្មដែលពួកគាត់បានចោទប្រកាន់ជនជាប់ចោទ ដោយ

កាន់អំពីការរំលោភសេពសន្ថវៈប៉ុណ្ណោះ ដែលត្រូវបានលើកឡើងប្រឆាំងនឹងជនជាប់ចោទនៅក្នុងផ្នែកដ៏ធំនៃដីកាដំណោះស្រាយដែលមានទាក់ទងនឹងការរំលោភសេពសន្ថវៈនៅក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំនោះ ការយោងនៅក្នុងផ្នែកសម្រេចសេចក្ដីចំពោះការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនៃ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ជាពិសេស [...] (ឆ) ការរំលោភសេពសន្ថវៈ"[40] ត្រូវតែអានដោយមានការកម្រិតដូចគ្នា។

២៥. នៅមុនសេចក្ដីសម្រេចនាពេលថ្មីៗរបស់ខ្លួន ការបកស្រាយនៃដីកាដំណោះស្រាយត្រូវបាន បញ្ជាក់ពីមុនចំនួនពីរដងរួចមកហើយ ដោយអង្គជំនុំជម្រះសាលាដំបូង[41] និងការបកស្រាយពីដីកា ដំណោះស្រាយនេះត្រូវបានយល់ឃើញដូចគ្នាដោយសហព្រះរាជអាជ្ញា[42]។ នៅពេលដែលពិចារណាអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹង ដីកាដំណោះស្រាយ អបជ ក៏បានយោងដល់ការយល់ឃើញរបស់ សចស ដែលបានកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្ដីពីការរំលោភសេពសន្ថវៈនៅក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំនោះ[43]។ តាមពិត សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងធ្លាប់បានប្រកាន់ទស្សនៈថា សចស បដិសេធចោលពីមុននូវការចោទប្រកាន់អំពី ការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ[44]។ សហព្រះរាជអាជ្ញា កត់សម្គាល់បន្ថែមថា*អង្គសេចក្ដី* នៃសេចក្ដីសន្និដ្ឋានរបស់ សចស មិនមែនជាប្រធានបទនៃបណ្ដឹងសាទុក្ខ

---

អនុលោមតាមទម្រង់នៃការទទួលខុសត្រូវមួយ ឬ ច្រើន ដែលបានចុះជាបញ្ជីនៅក្នុងដីកាដំណោះស្រាយ។ ដែលថាពួកគាត់មិនបានបកស្រាយបង្ហាញថា ពួកគាត់បានបដិសេធការលើកឡើងចោទប្រកាន់តាមអង្គហេតុនៃការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។

40 **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៦១៣។

41 **E306** សេចក្ដីសម្រេចរបស់ អជសដ ស្ដីពីអញ្ញត្រកម្ម, កថាខណ្ឌ៣ ("សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ការរំលោភសេពសន្ថវៈពុំកើតមានឡើងនៅមន្ទីរសន្តិសុខទេ ហើយបទល្មើសទាំងនេះមិនអាចយកមកធ្វើជាមូលដ្ឋានដើម្បីចោទប្រកាន់ចំពោះជនជាប់ចោទបានដែរ ដោយហេតុថាពុំមានភស្តុតាងគាំទ្រដែលថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យប្រើប្រាស់គោលនយោបាយការរំលោភសេពសន្ថវៈនៅក្នុងមន្ទីរសន្តិសុខឡើយ (ឯកសារ D427, កថាខណ្ឌ ១៤២៦-១៤២៨)។ ទោះបីជាអង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទដែលកំណត់ដែលបានកំណត់ក្នុងដីកាដំណោះស្រាយបានក៏ដោយ ក៏ប៉ុន្តែអង្គជំនុំជម្រះ *មិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ* (វិធាន៩៨(២) នៃវិធានផ្ទៃក្នុង)។ អង្គជំនុំជម្រះពុំមានសិទ្ធិអំណាចបញ្ចូលអង្គហេតុ ឬបទចោទថ្មីទៅក្នុងដីកាដំណោះស្រាយ ដែលអង្គហេតុ ឬបទចោទនោះត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត ហើយដែលអង្គបុរេជំនុំជម្រះពុំមានជំហរផ្សេងពីសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះ")។ **E348/4** សេចក្ដីសម្រេចរបស់ អជសដ សុំឲ្យមានការតទល់គ្នា។

42 សូមអាន ឧទា. **E319/40** ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារមួយចំនួន ពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/61, ២៩ មករា ២០១៦, កថាខណ្ឌ៦។ **E1/289.1** ប្រតិចារឹក ២១ មេសា ២០១៥, ទំព័រ ៨៣-៨៤។

43 **D427/1/30** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៦១។

44 **E99/1** ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីអំពើរំលោភសេពសន្ថវៈ, កថាខណ្ឌ៤០។

នេះទេ។ ពេលវេលា និងទីកន្លែងនៃការធ្វើអំណះអំណាងបែបដូច្នេះ គឺត្រូវធ្វើតាមបណ្តឹងសាទុក្ខពីដីកាដំណោះស្រាយដើម្បីដាក់ជូនទៅ អបជ។

២៦. បណ្តឹងសាទុក្ខរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសំណើពីមុន ទំនងជាមានមូលដ្ឋាននៅលើការមិនយល់គ្នាមួយនៃលក្ខខណ្ឌតម្រូវ សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកនូវការលើកឡើងចោទប្រកាន់អំពីអង្គហេតុ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ពេលអវត្តមាននៃដីកាមួយដែលមានបញ្ជាក់យ៉ាងច្បាស់អំពីការបដិសេធចោលនៅក្នុងដីកាដំណោះស្រាយ អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកនូវការលើកឡើងចោទប្រកាន់តាម អង្គហេតុណាមួយក៏ដោយដែល សចស បានរកឃើញនៅក្នុងដីកាដំណោះស្រាយថា បានបញ្ជាក់ រួចហើយដោយភស្តុតាងដែលបានប្រមូលនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[45]។ ជាលទ្ធផល ពួកគាត់បានអះអាងថា ខណៈដែល "អង្គជំនុំជម្រះសាលាដំបូងនៅមានឆន្ទានុសិទ្ធិដើម្បីកំណត់ប្រភេទនៃភស្តុតាងតាមមធ្យោបាយដែលខ្លួនយល់ថាសមស្រប ចំពោះការសម្រេចអំពីបទល្មើសដែលត្រូវបានចោទប្រកាន់ [...], ប៉ុន្តែ *saisine in rem* នៃការចោទប្រកាន់លើអង្គហេតុ ហូរដោយស្វ័យប្រវត្តិពីការបញ្ជូនដីកាដំណោះស្រាយទៅអង្គជំនុំជម្រះសាលាដំបូង"[46]។

២៧. យ៉ាងណាក៏ដោយ ដោយអនុលោមតាមវិធាន៧៩(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងទទួលយកតែដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយពី សចស ឬពី អបជ ប៉ុណ្ណោះ[47]។ និយាយ ម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែអាចទទួលយកអង្គហេតុទាំងឡាយណាដែល *ជនជាប់ចោទ*ត្រូវបាន *ចោទប្រកាន់* នៅក្នុងដីកាដំណោះស្រាយប៉ុណ្ណោះ។ គឺនៅ ក្នុងខ្លឹមសារនេះហើយដែលលក្ខខណ្ឌនៅក្នុងវិធាន៦៧(២) នៃវិធានផ្ទៃក្នុងបានកំណត់ដូចគ្នាទៅនឹងបរិបទនៃដំណោះស្រាយដែលគួរត្រូវបកស្រាយ។ ការណ៍ទាំងនេះ ចែងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវតែរៀបរាប់ពីអង្គហេតុសំខាន់ *និង ការកំណត់បទចោទរបស់វា* ដោយ កសចស រួមមាន បទបញ្ញត្តិព្រហ្មទណ្ឌដែលពាក់ព័ន្ធ និង *ចរិកលក្ខណៈនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ*[48]។ ក្រម នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ("CPC") មានបទបញ្ញត្តិស្រដៀងគ្នាមួយ នៅក្នុងមាត្រា២៤៧[49]។ តាមពិត ដីកាដំណោះស្រាយមួយត្រូវតែមាន

---

[45] សូមអាន ឧទា. **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៥១-៥២, ៥៩, ៧៨-៧៩។ **E306/7** សារណា, កថាខណ្ឌ១០, ១២, ១៨, ២២, ២៣, ២៥។ **E306/7** ការឆ្លើយតប, កថាខណ្ឌ៦។

[46] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៧៨។

[47] ការណ៍នេះក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធានផ្ទៃក្នុង៦៧(១) នៃវិធានផ្ទៃក្នុង ផងដែរ ដែលចែងថា "សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"។

[48] វិធាន៦៧(២) នៃវិធានផ្ទៃក្នុង។

[49] CPC, មាត្រា២៤៧ ("ប្រសិនបើ [ចៅក្រមស៊ើបសួរ] យល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទ ទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់")។

ធាតុផ្សំចាំបាច់ទាំងអស់ដើម្បីធានាពីសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានព័ត៌មានអំពីចរិកលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងពួកគាត់[50] ដែលត្រូវតែបានពិចារណាផងដែរ ទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការត្រៀមរៀបចំនូវកិច្ចការពាររបស់ពួកគាត់[51]។

២៨. ដូច្នេះ ដីកាដំណោះស្រាយមួយត្រូវតែជូនដំណឹងដល់ជនជាប់ចោទ *ទាំងស្រុង និង យ៉ាងពិស្តារ* មិនត្រឹមតែពីអំពើដែលពួកគាត់ត្រូវបានលើកឡើងចោទប្រកាន់ថាបានប្រព្រឹត្ត និងដែលនៅលើនោះការចោទប្រកាន់ត្រូវមានមូលដ្ឋានប៉ុណ្ណោះទេ ក៏ប៉ុន្តែ ថែមទាំងការកំណត់បទចោទដែលបានឆ្លើយតបទៅអំពើទាំងនោះផងដែរ[52]។ "ការកំណត់បទចោទ" *រួមមាន* ទាំងចំណាត់ថ្នាក់នៃឧក្រិដ្ឋកម្ម *និង* ទាំងទម្រង់នៃការទទួលខុសត្រូវ ដែលនៅក្រោមនោះ ជនជាប់ចោទត្រូវបានចោទប្រកាន់[53]។ ដូចដែល អបជ បានសន្និដ្ឋានថា៖

50 ច្បាប់ *អវតក*, មាត្រា៣៥*ថ្មី*។ ICCPR, មាត្រា១៤(៣)(ក)។ ECHR, មាត្រា៦(៣)(ក)។ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ ឌុច, ៥ ធ្នូ ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើសំណុំរឿង០០១"), កថាខណ្ឌ៤៧, ៥០។ **D97/15/9** សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ២០ ឧសភា ២០១០ ("សាលដីកាលើ JCE"), កថាខណ្ឌ៣១-៣២។

51 ច្បាប់ *អវតក*, មាត្រា៣៥*ថ្មី*។ ICCPR, មាត្រា១៤(៣)(ខ)។ ECHR, មាត្រា៦(៣)(ខ)។ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើសំណុំរឿង០០១, កថាខណ្ឌ៤៧។ **D97/15/9** សាលដីកាលើ JCE, កថាខណ្ឌ៣១-៣២។ *Pélissier និង Sassi ទល់នឹង ប្រទេសបារាំង,* លេខ 25444/94, សាលក្រម, ២៥ មីនា ១៩៩, ("*Pélissier*"), កថាខណ្ឌ៥៤។ *Sipavičius ទល់នឹង ប្រទេស លីទុយអានី,* លេខ 49093/99, សាលក្រម, ១០ កក្កដា ២០០២ ("*Sipavičius*"), កថាខណ្ឌ២៨។

52 វិធាន៦៧(២) នៃវិធានផ្ទៃក្នុង។ *Pélissier*, កថាខណ្ឌ៥១-៥២, ៥៤ ("*ភាពជាក់លាក់នៃបទល្មើសដើរតួសំខាន់នៅក្នុងនីតិវិធីព្រហ្មទណ្ឌ នៅក្នុងនោះគឺវាចាប់តាំងពីពេលនៃសេវារបស់វាដែលជនសង្ស័យត្រូវបានដាក់ការជូនដំណឹងតាមផ្លូវច្បាប់ស្តីពី មូលដ្ឋានតាមអង្គហេតុ និងអង្គច្បាប់* នៃការចោទប្រកាន់ប្រឆាំងនឹងគាត់។ មាត្រា៦§៣(ក) នៃអនុសញ្ញាល្មមនឹងលៃលកឲ្យជនជាប់ចោទត្រូវបានទទួលសិទ្ធិក្នុងការជូនដំណឹង មិនត្រឹមតែមូលហេតុនៃការចោទប្រកាន់ប៉ុណ្ណោះទេ គឺថាអំពើដែលខ្លួនត្រូវបានលើកឡើងចោទប្រកាន់ថាបានប្រព្រឹត្ត និងដែលនៅលើនោះ ការចោទប្រកាន់ត្រូវមានមូលដ្ឋាន ក៏ប៉ុន្តែថែមទាំងការកំណត់បទចោទដែលបានផ្តល់ឲ្យទៅអំពោះទាំងនោះថែមទៀតផង។ ព័ត៌មានទាំងនោះត្រូវ [...] តែបានធ្វើឲ្យពិស្តារ [...]។ តុលាការពិចារណាថា នៅក្នុងបញ្ហាបទឧក្រិដ្ឋ បទបញ្ញត្តិទាំងស្រុង ព័ត៌មានពិស្តារអំពីការចោទប្រកាន់ប្រឆាំងនឹងអ្នកប្រព្រឹត្តបទល្មើស ហើយដូច្នេះ ការកំណត់បទចោទដែលតុលាការអាចនឹងទទួលយកទៅអនុវត្តក្នុងបញ្ហានេះ គឺជាអ្វីដែលត្រូវការជាមុនដ៏សំខាន់សម្រាប់ធានាថា កិច្ចដំណើរការនីតិវិធីគឺត្រឹមត្រូវ")។ *Dallos ទល់នឹង ប្រទេសហុងគ្រី,* លេខ 29082/95, សាលក្រម, ១ មីនា ២០០១ ("*Dallos*"), កថាខណ្ឌ៤៧។ *Sipavičius*, កថាខណ្ឌ២៧-២៨។

53 វិធាន៦៧(២) នៃវិធានផ្ទៃក្នុង។

ក្នុងករណីមានការចោទប្រកាន់ថា ជនជាប់ចោទបានរៀបចំផែនការ ញុះញង់ បង្គាប់បញ្ជា ឬ ជួយ និង ទំនុកបម្រុង នៅក្នុងការប្រព្រឹត្តបទល្មើសដែលចោទប្រកាន់, "អំពើជាក់លាក់" ឬ "ការប្រព្រឹត្តជាក់លាក់" របស់ជនជាប់ចោទ ដែលបង្កើតជាទម្រង់នៃបទចោទដែលមានភាពចម្រុងចម្រាស់នេះ ត្រូវតែបង្ហាញចេញ។ ការចោទប្រកាន់លើការទទួលខុសត្រូវរបស់ថ្នាក់លើ មិនត្រឹមតែទាមទារធាតុផ្សំថា អ្វីទៅដែលគេចោទថាជាការប្រព្រឹត្តផ្ទាល់របស់ថ្នាក់លើប៉ុណ្ណោះទេ វាថែមទាំងទាមទារថា អ្វីទៅដែលគេចោទថាជាការប្រព្រឹត្តរបស់បុគ្គលដទៃ ដែលបុគ្គលថ្នាក់លើត្រូវទទួលខុសត្រូវ ដោយធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាន[54]។

២៩. ដូច្នេះ មិនអាចចោទប្រកាន់ចំពោះអំពើអកម្មបាននោះទេ ហើយការលើកឡើងចោទប្រកាន់ពីអង្គហេតុមិនអាចធ្វើបានដោះការខ្វះចន្លោះនៅក្នុងដីកាដំណោះស្រាយ ដោយគ្មានលក្ខណៈជាឧក្រិដ្ឋកម្មជាក់លាក់មួយ ឬទំនាក់ទំនងទៅនឹងជនជាប់ចោទតាមរយៈទម្រង់នៃ ការទទួលខុសត្រូវមួយបានទេ។ ឬក៏ មិនជូនដំណឹងដល់ជនជាប់ចោទអំពីការកំណត់បទចោទនៃ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយអាទិចារី បង្កើតបានជាការជូនដំណឹងយ៉ាងពេលលេញនៃការ ចោទប្រកាន់ប្រឆាំងនឹងពួកគាត់។ ដូចដែលបានថែងនៅខាងលើ ដោយការខកខានមិនបានភ្ជាប់ ជនជាប់ចោទទៅនឹងឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈនៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ តាមរយៈការរកឃើញតាមអង្គហេតុ និងអង្គច្បាប់ ដែលមានជាប់ទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវណាមួយនោះ ដីកាដំណោះស្រាយ *មិនមានបទចោទប្រកាន់ជាវិជ្ជមាន* ឬមានហេតុផលដែលអាចគាំទ្រដល់ការចោទប្រឆាំងនឹងជនជាប់ចោទនោះទេ។ វា*មិន* គ្រប់គ្រាន់នោះទេដែលថា អាចនឹងមាន "ការចង្អុលបង្ហាញអំពីភាពមិនគ្រប់គ្រាន់នៃ គោលនយោបាយ [រារាំង និង ផ្តន្ទាទោសដល់ការរំលោភសេពសន្ថវៈ]"[55] ឬក៏ សចស "[បានទុក]ឲ្យអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិក្នុងការពិចារណា" មិនថាជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ នៅក្រោមសហឧក្រិដ្ឋកម្មរួម ឬក៏ការទទួលខុសត្រូវរបស់ថ្នាក់លើ (ឬ ដោយការសន្មតថា តាមទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត)[56]។

៣០. កំហុសឆ្គងដដែលនេះគាំទ្រដល់វិធីសាស្ត្ររបស់ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់បទចោទសារជាថ្មីឡើងវិញ។ ជាបញ្ហាគោលការណ៍ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានអះអាងយ៉ាងត្រឹមត្រូវថា "បទចោទក្នុងដីកាដំណោះស្រាយ ដែលរួមបញ្ចូលឧក្រិដ្ឋកម្មសំខាន់ និងទម្រង់នៃការទទួលខុសត្រូវ ដើរតួនាទីជាសំណើមួយរបស់ [សចស] ទៅអង្គជំនុំជម្រះសាលាដំបូង។ ដរាបណាជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវអំពីបទចោទទាំងនេះ ឧក្រិដ្ឋកម្មសំខាន់នានា និងទម្រង់នៃការទទួលខុសត្រូវ

54 **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើសំណុំរឿង០០១, កថាខណ្ឌ៤៩។

55 **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៥៥។

56 **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៥៤-៥៦។

ពាក់ព័ន្ធអាចត្រូវបានកំណត់ឡើងវិញ តាមរយៈឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង"[57]។ យ៉ាងណាក៏ដោយ នៅទីកន្លែងផ្សេងៗនៅក្នុងខ្លឹមសារនៃបណ្តឹងសាទុក្ខ និងនៅក្នុងសំណើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទំនងជាសន្មតសិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង មិនត្រឹមតែអាចកំណត់បទចោទ ការរំលោភសេពសន្ថវៈសារជាថ្មីឡើងវិញ[58] ថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស" និង/ឬ "ការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[59]ទេ ក៏ប៉ុន្តែថែមទាំងយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាចទាក់ទងនឹង "ការជ្រើសរើស *និង ការកំណត់*ទម្រង់នៃការទទួលខុសត្រូវ *ទៅនឹងការរកឃើញបទល្មើសសំខាន់ៗដែលពាក់ព័ន្ធ*"[60] ថែមផងដែរ។ ការណ៍នេះ នឹងធ្វើឲ្យមានការភ័ណ្ឌច្រឡំនូវអំណាចស្របច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង នៅក្រោមវិធាន៩៨(២) នៃវិធានផ្ទៃក្នុង *ឲ្យកំណត់បទចោទសារជាថ្មីឡើងវិញ* ឬ *ផ្លាស់ប្តូរការកំណត់បទចោទ* នៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលបានកំណត់ដោយ សចស នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយអង្គជំនុំជម្រះសាលាដំបូងគ្មានអំណាចជាអត្ថិភាពដើម្បី *កំណត់បទចោទលើអង្គហេតុ* ដែល សចស មិនបានចង្អុលបង្ហាញនៅក្នុងដីកាដំណោះស្រាយនោះទេ។ ដូចដែលវាមានជាប់មកជាមួយនូវពាក្យ "កំណត់បទចោទ*សារជាថ្មីឡើងវិញ*" ត្រូវតែមានជាឧក្រិដ្ឋកម្មមួយ ឬក៏ មានទម្រង់នៃការទទួលខុសត្រូវមួយ ដែលមានទំនាក់ទំនងទៅនឹងអង្គហេតុ ដែលត្រូវតែមាន "ចរិកលក្ខណៈ" មួយមុនពេលដែលអាច "កំណត់បទចោទសារជាថ្មីឡើងវិញ"បាន។ នៅក្នុងករណីនេះ ទោះបីជា សចស បានធ្វើការចោទប្រកាន់លើអង្គហេតុស្របច្បាប់ពីការរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏ការកំណត់បទចោទសារជាថ្មីឡើងវិញ គ្មានចរិកលក្ខណៈ ចំពោះមធ្យោបាយរបស់ជនជាប់ចោទ ក្នុងការចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនោះ តាមរយៈទម្រង់នៃការទទួលខុសត្រូវណាមួយនោះទេ។

៣១. ការអះអាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលថា អង្គជំនុំជម្រះសាលាដំបូងមានការខុសឆ្គងក្នុងការដោះស្រាយលើបញ្ហាអំពីការកំណត់បទចោទសារជាថ្មីឡើងវិញ ជាជាងវិសាលភាពនៃអង្គហេតុនៃសំណើរឿង០០២/០២ និងតាមរយៈនេះ ខកខានមិនបានផ្តល់នូវសេចក្តី

---

[57] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៩១ *ដោយលើកឡើងពី* វិធាន៩៨។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងអាចនឹងប្តូរការកំណត់បទចោទនៃឧក្រិដ្ឋកម្មដែលបានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កុំឲ្យតែមានធាតុផ្សំចាំបាច់ថ្មីត្រូវបានដាក់បញ្ចូល។

[58] នៅក្នុងដីកាដំណោះស្រាយ សចស បានកំណត់បទចោទលើការលើកឡើងចោទប្រកាន់ទាំងនេះ - និងការកំណត់បទចោទលើការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ - ថាជាការរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដែលខុសគ្នា។ នៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ អបជ បានផ្លាស់ប្តូរការកំណត់បទចោទ ទៅជា អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈ ការរំលោភសេពសន្ថវៈ។ សូមអាន *ខាងដើម,* កថាខណ្ឌ៥។

[59] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៥៨។ **E306/7** សំណើ, កថាខណ្ឌ២៥។

[60] **E306/7** សំណើ, កថាខណ្ឌ២៥។ **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៥៨, ៩០។

សម្រេចមួយដែលមានសំអាងហេតុស្តីពីបញ្ហានៃ *saisine*[61] ឬដោយការសន្និដ្ឋានថា ជនជាប់ចោទមិនត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ចំពោះការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ[62] ដូច្នេះ ត្រូវតែបរាជ័យទាំងពីរ។ សហព្រះរាជអាជ្ញា យល់ស្របជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នូវសំនួរអំពី "*saisine* មានមុនការកំណត់បទចោទ [របស់អង្គជំនុំជម្រះសាលាដំបូង]"[63] និងថា "អង្គជំនុំជម្រះសាលាដំបូងពុំមានសិទ្ធិដើម្បីកំណត់បទចោទឡើងវិញ អំពីការចោទប្រកាន់លើ អង្គហេតុដែលខ្លួនពុំត្រូវបានប្តឹងឲ្យពិនិត្យ និងចាត់ការត្រឹមត្រូវជាមុននោះទេ"[64]។ នៅក្នុងសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងមិនបានមើលរំលងនូវលំដាប់យ៉ាងសមហេតុសមផលនេះទេ ហើយបានទទួលស្គាល់យ៉ាងជាក់ច្បាស់នូវសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យបញ្ជាក់ថា អជសជ "បានទទួលការចោទប្រកាន់ជាផ្លូវការលើអង្គហេតុនៃការរំលោភសេពសន្ថវៈនៅសហករណ៍ត្រាំកក់ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ នៅក្នុងសំណុំរឿង០០២/០២"[65]។ អនុលោមទៅតាមសំណើនោះ បានផ្តល់នូវសេចក្តីសម្រេចមួយដែលត្រឹមត្រូវ និងមានសំអាងហេតុទាក់ទងទាំង *saisine* របស់វា ព្រមទាំងអំណាចរបស់វា នៅក្នុងការកំណត់បទចោទសារជាថ្មីឡើងវិញនូវឧក្រិដ្ឋកម្មនានា ទៅតាមលំដាប់លំដោយនោះ[66]។

៣២. អង្គជំនុំជម្រះសាលាដំបូងបានរកឃើញយ៉ាងត្រឹមត្រូវនៅក្នុងដដីកាដំណោះស្រាយថា មាន "សំអាងហេតុច្បាស់លាស់ពី ការរំលោភសេពសន្ថវៈនៅក្រៅការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" នៅតាមទីតាំងនានា រួមទាំង សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខ ស-២១ និងក្រាំងតាចាន់ ហើយត្រូវបានកំណត់បទចោទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ[67]។ ក្រោយមក ខ្លួនបានបន្តទៅសម្រេចថា សចស មិនបានភ្ជាប់ឧក្រិដ្ឋកម្មទាំងនេះទៅនឹងជនជាប់ចោទ នោះទេ[68]។ ដូច្នេះ អង្គជំនុំជម្រះនេះបានសន្និដ្ឋានថា អង្គហេតុទាំងនេះគឺត្រូវបាន "បដិសេធដោយ [សចស] ដែលជាសេចក្តីសម្រេចមួយមិនបានរំខានដោយ [អបជ]ទេ"[69] ហើយក៏ "មិនត្រូវបានចោទប្រកាន់ក្នុងដីកា

---

[61] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៧៤-៧៥។

[62] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៨២-៩១។

[63] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៧៦។

[64] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៧៦។

[65] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១ *ដោយលើកឡើងពី* **E306/7** សារណា, កថាខណ្ឌ១៦-១៧, ២៨។

[66] សូមអានជាពិសេស **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១១ ("នៅមុនពេលធ្វើការសម្រេចណាមួយលើការកំណត់បទចោទ អង្គជំនុំជម្រះត្រូវធ្វើការកំណត់លើអង្គហេតុជាក់លាក់នានា ដែលជាមូលដ្ឋានដែលជនជាប់ចោទ ត្រូវបានចោទប្រកាន់ជាផ្លូវការ")។

[67] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៣-១៤។

[68] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៤-១៥។ សូមអានផងដែរ កថាខណ្ឌ១៧។

[69] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៧ យោងសេចក្តីសម្រេចពីមុនរបស់ខ្លួនស្តីពីចំណុចនេះ, **E306** សេចក្តីសម្រេចរបស់ អជសជ ស្តីពីអញ្ញត្រកម្ម, កថាខណ្ឌ៣។

ដំណោះស្រាយ"[70]ដែរ មានន័យថា អង្គជំនុំជម្រះសាលាដំបូងមិនត្រូវបានប្តឹងតាមរយៈអង្គហេតុទាំងនោះ[71]។ គឺនៅពេលនោះហើយដែលបានកំណត់ថា អង្គហេតុទាំងនោះមិនស្ថិតនៅក្នុងសិទ្ធិអំណាចរបស់អង្គជំនុំជម្រះដើម្បីកំណត់បទចោទសារជាថ្មីឡើងវិញនូវអង្គហេតុនានាដែលមិនត្រូវបានប្តឹង[72]។ អង្គជំនុំជម្រះសាលាដំបូងមិនបានខុសឆ្គងនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានដើរគ្រប់ជំហានដែលតម្រូវ ហើយបានធ្វើសេចក្តីសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ខ្លួនមិនទទួលយកនូវការចោទប្រកាន់តាមអង្គហេតុនៃការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។

*អានុភាពនៃដីកាសម្រេចបំបែកសំណុំរឿងបន្ថែម*

៣៣. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីសង្ឃឹម[73] ទៅលើអង្គហេតុត្រង់កថាខណ្ឌ ១៤២៦-១៤២៨ (ការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ) ត្រូវបានរួមបញ្ចូលនៅក្នុងវិសាលភាពនៃបញ្ជីកថាខណ្ឌ និងផ្នែកដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ ដែលបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ទាក់ទងនឹងស-២១ ក្រាំងតាចាន់ និង សហករណ៍ត្រាំកក់[74]។ យ៉ាងណាក៏ដោយ ការណ៍នេះគឺច្បាស់ណាស់ថាជាកំហុសមួយ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន "ដីកាបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម មិនមានដាក់បញ្ចូលការចោទប្រកាន់លើការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមិនត្រូវបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយនោះឡើយ"[75]។ តាមពិត នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ គឺបីសប្តាហ៍ក្រោយមក អង្គជំនុំជម្រះសាលាដំបូង ខ្លួនឯងបានចេញនូវសេចក្តីសម្រេចមួយដោយបញ្ជាក់ថា ខ្លួនមិនបានពិចារណាថាជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្ម ស្តីពីការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ[76]។ ខ្លួនបានធ្វើម្តងទៀតអំពីបញ្ហានេះ នៅខែមិថុនា ឆ្នាំ២០១៥[77]។

៣៤. នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ ចំពោះគ្រប់មូលហេតុទាំងអស់ដែលបានរាយនៅខាងលើនេះ អង្គជំនុំជម្រះសាលាដំបូងមិនមានអំណាច តាមរយៈបញ្ជីអង្គហេតុនេះ ឬផ្សេងពីនេះក៏ដោយ បន្ថែមនូវអង្គហេតុ ដែលជនជាប់ចោទអាចត្រូវបានរកឃើញថា ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះ

[70] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៥, ១៦, ១៧, ១៩។

[71] វិធាន៧៩(១) នៃវិធានផ្ទៃក្នុង។

[72] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៩, ទំព័រ៨។

[73] **E306/7/3/1/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ១២, ៥៩។ **E306/7** សំណើ, កថាខណ្ឌ១៤, ២១, ២៣, ២៨។

[74] **E301/9/1.1** ឧបសម្ពន្ធនៃវិសាលភាពនៃសំណុំរឿង០០២/០២, កថាខណ្ឌ៥(ii)(១០)។

[75] **E306/7/3** សេចក្តីសម្រេច, កថាខណ្ឌ១៧។

[76] **E306** សេចក្តីសម្រេចរបស់ អជសដ ស្តីពីអញ្ញត្រកម្ម, កថាខណ្ឌ៣។

[77] **E348/4** សេចក្តីសម្រេចរបស់ អជសដ សុំឲ្យមានការតទល់គ្នា, កថាខណ្ឌ១១។

វិសាលភាពនៃសំណុំរឿង០០២/០២ (ឬ ចំពោះសំណុំរឿង០០២ ជាទូទៅ) ដែលអង្គហេតុនេះមិនត្រូវបានប្ដឹងដោយ សចស នៅក្នុងដីកាដំណោះស្រាយ។

*សំណើ និង បណ្ដឹងសាទុក្ខ*
*ប្រឈមនឹងការពន្យារពេលយ៉ាងច្រើននៅក្នុងសវនាការលើសំណុំរឿង០០២/០២*

៣៥. ដូចបានថែងនៅខាងលើ នៅក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូងត្រូវមានពេលពីរដងគឺនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤[78] (មានរយៈពេលប្រាំបីខែមុនសក្ខីកម្មបានចាប់ផ្ដើម) និងម្ដងទៀតនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៥[79] ដើម្បីបញ្ជាក់ថា ខ្លួនមិនបានត្រូវប្ដឹងសុំឱ្យពិចារណាទទួល យកការចោទប្រកាន់តាមអង្គហេតុ ស្ដីពីការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងសំណុំរឿង០០២ទេ។ នៅក្នុងឱកាសនីមួយៗសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មិនបានស្វែងរកដាក់បណ្ដឹងសាទុក្ខលើការរកឃើញនោះទេ។ ការដាក់សំណើនេះដែលយឺតយ៉ាវនៅក្នុងកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២/០២ ដើម្បីសុំការបញ្ជាក់លើបញ្ហាមួយដែលនៅលើបញ្ហានោះអង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចទៅហើយ នោះវាបង្កើតឱ្យមានហានិភ័យជាដល់ការពន្យារពេលយ៉ាងច្រើន នៅក្នុងការបញ្ចប់សវនាការនៃសំណុំរឿង០០២/០២។

៣៦. ដើម្បីសង្ខេបឱ្យបានខ្លីអំពីមូលហេតុទាំងឡាយសម្រាប់ការប្រឈមនោះ អជតក ត្រូវបានតម្រូវឱ្យចេញនូវសាលដីកាមួយលើបញ្ហានេះក្នុងរយៈពេលបី (ឬ នៅក្នុងកាលៈទេសៈលើកលែង បួន) ខែនៃការបញ្ជូនសំណុំរឿងទៅពិនិត្យ ដោយអង្គជំនុំជម្រះសាលាដំបូង[80]។ ដូច្នេះ សាលដីកាមួយអាចត្រូវបានគេរំពឹងថានឹងមាននៅពេលណាមួយ រហូតដល់ពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ២០១៧ (សន្មត់ថា អង្គជំនុំជម្រះមានសមាសភាពពេញលេញ)។ ច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូងមិនអាចនឹងប្រកាសថាភស្តុតាងត្រូវបានបិទនោះទេ រហូតទាល់តែបានទទួលនូវសាលដីកាពី អជតក ថាតើខ្លួនចាំបាច់ត្រូវវិនិច្ឆ័យសេចក្ដីលើបទចោទបន្ថែមដែលបានលើកឡើងចោទប្រកាន់នេះដែរ ឬមួយយ៉ាងណា។ ដូច្នេះ បើទោះជាត្រូវបានបដិសេធក្ដី ក៏បណ្ដឹងសាទុក្ខទំនងជានឹងត្រូវពន្យារពេលដល់ការបញ្ចប់សវនាការក្នុងសំណុំរឿង០០២/០២ដែរ។

៣៧. ម៉្យាងវិញទៀត បើសិនជាបណ្ដឹងសាទុក្ខបានជោគជ័យ វាមានសេណារីយ៉ូមួយដែលសហព្រះរាជអាជ្ញាប្រមើលមើលឃើញថា វាមិនសូវជាទំនងទាល់តែសោះ ដោយសារកង្វះអង្គច្បាប់នៅក្នុងអំណះអំណាងនៃបណ្ដឹងសាទុក្ខនោះ ការពន្យារពេលយ៉ាងច្រើនថែមទៀតដល់កិច្ចដំណើរការនីតិវិធីគឺប្រាកដជានឹងកើតមានជាមិនខាន។ ការសម្រេចមួយដែលនឹងធ្វើឱ្យមានការផ្លាស់ប្ដូរវិសាលភាព

---

78 **E306** សេចក្ដីសម្រេចរបស់ អជសដ ស្ដីពីអញ្ញត្រកម្ម, កថាខណ្ឌ៣។

79 **E348/4** សេចក្ដីសម្រេចរបស់ អជសដ សុំឱ្យមានការតទល់គ្នា, កថាខណ្ឌ១១។

80 វិធាន១០៨(៤*ស្ទួន*)(ខ) នៃវិធានផ្ទៃក្នុង។

នៃសំណុំរឿង០០២/០២ដើម្បីបញ្ចូលបទចោទថ្មីៗ ប្រាកដណាស់ថាវានឹងបញ្ចេះឲ្យមានកាតព្វកិច្ច មួយដែលត្រូវធ្លាក់ទៅលើសហព្រះរាជអាជ្ញា ក្នុងការត្រួតពិនិត្យសារជាថ្មីឡើងវិញលើគ្រប់សម្ភារៈទាំងអស់ដែលនៅមិនទាន់បានដាក់បង្ហាញដល់ភាគីនានានៅក្នុងសំណុំរឿង០០២ សម្រាប់ភាពពាក់ព័ន្ធទៅនឹងការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។

៣៨. សហព្រះរាជអាជ្ញាអន្តរជាតិ ("សពអ") ប៉ាន់ស្មានថា បច្ចុប្បន្នមានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ៣.៦០០ ច្បាប់ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង ព័ត៌មានបន្ថែម ហើយនិង បទសម្ភាសន៍របស់ DC-Cam លើសំណុំរឿង០០៣ និង ០០៤ ដែលជាចាំបាច់ត្រូវតែពិនិត្យមើលឡើងវិញ ដើម្បីបំពេញកាតព្វកិច្ច។ នៅពេលដែលការពិនិត្យមើលឡើងវិញនោះចប់សព្វគ្រប់ ការអនុញ្ញាតមួយនឹងត្រូវបានតម្រូវឲ្យមានពីសំណាក់ សចស ដើម្បីដាក់បង្ហាញរាល់ឯកសារដែលពាក់ព័ន្ធទាំងអស់ ជូនទៅភាគីនានានៃសំណុំរឿង០០២ និង អង្គជំនុំជម្រះសាលាដំបូង។ ប្រមាណជា ១៤ នៃសំណើថ្មីៗរបស់ សពអ សម្រាប់ការអនុញ្ញាតដាក់បង្ហាញឯកសារដែលបានប្តឹងដោយភាគីនានានៃសំណុំរឿង០០៣ និង ០០៤ - រួមមាន បណ្តឹងឧទ្ធរណ៍មួយចំនួន ទៅកាន់ អបជ ផង នឹងបណ្តាលឲ្យមានការពន្យារពេលយ៉ាងច្រើនចំពោះលទ្ធភាពរបស់ សពអ ក្នុងការផ្តល់នូវការដាក់បង្ហាញជូនភាគីនានានៃសំណុំរឿង០០២។ ជាលទ្ធផល ដំណើរការនៃការដាក់បង្ហាញបន្ថែមតែឯង មុខជានឹងពន្យារពេល យ៉ាងជាក់ច្បាស់ដល់ការបញ្ចប់ភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ យ៉ាងហោចណាស់ក៏អស់ ជាច្រើនខែដែរ។

៣៩. ផ្អែកលើការដាក់បង្ហាញកន្លងមក ជនជាប់ចោទ នៅពេលនោះ ទំនងជាស្នើសុំពេលវេលាបន្ថែមសម្រាប់ពិនិត្យមើលឯកសារថ្មីនេះ និងធ្វើសំណើសុំភ្ជាប់សម្រាប់ការទទួលយកភស្តុតាង អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ ក្នុងបំណងនិយាយពីការបង្ហាញសក្ខីកម្មអំពីបទចោទ "ថ្មី" សហព្រះរាជអាជ្ញាក៏ប្រមើលទុកជាមុនផងដែរ នូវការដាក់សំណើជូនអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការទទួលយកភស្តុតាង ដែលជាប់ទាក់ទងនឹងការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ភាគីនានាក៏អាចស្វែងរកធ្វើការកោះហៅ(ឬកោះហៅសារថ្មីឡើងវិញ) នូវសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ អ្នកជំនាញនានាផងដែរ ទាក់ទងនឹងទិដ្ឋភាពបន្ថែមនៃផ្នែក ស-២១ ក្រាំងតាចាន់ និង សហករណ៍ត្រាំកក់ នេះ។

៤០. ដូច្នេះ ការពន្យារពេលដែលបណ្តាលមកពីការបន្ថែមការរំលោភសេពសន្ថវៈនៅខាងក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ នៅដំណាក់ការចុងក្រោយនៅក្នុងសវនាការលើសំណុំរឿង០០២/០២ គឺប្រាកដជាសំខាន់ខ្លាំងណាស់ ហើយវានឹងផ្អាកបន្ថែមទៀតនូវយុត្តិធម៌ដែលជនរងគ្រោះបាននឹងកំពុងរង់ចាំអស់រយៈពេលបួនទសវត្សរ៍មកហើយ។

## V. ដំណោះស្រាយដែលស្នើសុំ

៤១. ចំពោះហេតុផលនានាដែលបានថ្លែងនៅខាងលើនេះ សហព្រះរាជអាជ្ញា ស្នើសុំឲ្យ អជតក បដិសេធបណ្តឹងសាទុក្ខនេះចោល៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |